JICA កម្ពុជា

# គំរោងពង្រឹងប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល

The Project for Strengthening Human Resources Development System of Co-medicals

ព្រឹត្តប័ត្រពត៌មានពីគំរោង JICA HRD　　លេខ ១　　ខែកក្កដា ២010

### តើពាក្យថា Co-medicals មានន័យដូចម្តេច?

ពាក្យថា អមវេជ្ជសាស្ត្រ Co-Medicals មានប្រភពមកពីពាក្យអង់គ្លេស បែបជប៉ុន ដែលតាមរយៈវចនានុក្រមភាសាជាតិរបស់ ជប៉ុន (大辞林)(三省堂) មានន័យថា បុគ្គលិក អមវេជ្ជសាស្ត្រ ដែលរួមមានបុគ្គលិកបច្ចេកទេសសុខាភិបាល ក្រៅពីវេជ្ជបណ្ឌិត ឱសថការី និង ទន្តបណ្ឌិត។ នៅក្នុង Co-Medicals ពាក្យថា Co មានន័យថា សហ រឺ អម។ ប៉ុន្តែនិយាយអោយទូលាយទៅ គឺសំដៅទៅលើអ្នកធ្វើការងារផ្នែកវេជ្ជសាស្ត្រទាំងឡាយណា ក្រៅពី វេជ្ជបណ្ឌិត ឱសថការី និង ទន្តបណ្ឌិត។ ពាក្យ Co-Medicals ក៏អាចហៅ បានថា Paramedicals ជាភាសា អង់គ្លេស។

## គោលដៅនៃគំរោង

គំរោង ពង្រឹងប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាលធ្វើការផ្តោតលើការពង្រឹង ប្រព័ន្ធបណ្តុះបណ្តាលសមត្ថភាព គ្រូបង្រៀនថ្មី និង គ្រូបង្រៀន ដែល-មានស្រាប់ ជាពិសេសគ្រូបង្រៀនផ្នែក គិលានុបដ្ឋាក និង ឆ្មប។

គំរោងមិនត្រឹមតែ ធ្វើការពង្រឹង សមត្ថភាពគ្រូបង្រៀនអោយកាន់តែមានប្រសិទ្ធិភាព ប៉ុណ្ណោះទេ គឺថែមទាំងមាន គោលដៅលើកស្ទួយប្រព័ន្ធនៃ ការអភិវឌ្ឍន៍ធនធានមនុស្ស ផ្នែកអមវេជ្ជសាស្ត្រផងដែរ។ ដូច្នេះការិយាល័យនៃគំរោងស្ថិតនៅក្នុង នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល។

គំរោងនេះមានទស្សនៈវិស័យយូរអង្វែងលើការ ពង្រឹងច្បាប់ជាមូលដ្ឋាន ទាក់ទងនឹងប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្ស ដែលជាគោលការណ៍ចាំបាច់មិនអាចខ្វះបាន ក្នុងការអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល។

ការពង្រឹងសមត្ថភាពគ្រូបង្រៀន និង ការរៀបចំច្បាប់ទាក់ទងនឹង ការអភិវឌ្ឍន៍ ធនធានមនុស្ស ទាំង២នេះជាការងារចំបងរបស់ គំរោង។ ការងារគំរោង លំអិត-សូមមើល HP នៃគំរោង។

## ការរៀបចំការិយាល័យគំរោង

ពេលចាប់ផ្តើមដំបូងនៃគំរោង ចាំបាច់ត្រូវរៀបចំ ការិយាល័យជាមុនសិន។ ការិយាល័យគំរោងមាន ២ បន្ទប់ ដែលបន្ទប់មួយជារបស់លោកអនុប្រធាននាយកដ្ឋាន និង បន្ទប់មួយទៀត ជាអតីតឃ្លាំងដែលត្រូវបានរៀបចំជាការិយាល័យគំរោង ផងដែរ។ ដោយសារតែសំភារៈគរដូចភ្នំ ដូចនេះហើយ ការរៀបចំ ត្រូវចំណាយពេល ៤ ថ្ងៃ ដែលមាន សកម្មភាព ដូចរូបខាងក្រោម ។ ក្រោយការរៀបចំ ការិយាល័យ របស់គំរោងក៏បានលេចចេញជារូបរៀងឡើង ។ សំភារៈដែលប្រើប្រាស់ក្នុងការិយាល័យគំរោង គឺស្ទើរតែទាំងអស់ជាសំភារៈដែលទុកក្នុងឃ្លាំងនេះ។ ចំពោះ ម៉ាស៊ីនថតចំឡងវិញ គឺខ្ចីពីការិយាល័យ Jica ប្រចាំនៅកម្ពុជា ហើយសំភារៈចាស់ៗត្រូវបានប្រើ ឡើងវិញក្នុងគោលបំនងសន្សំសំចៃ។



ទិដ្ឋភាពក្នុងឃ្លាំងមុនរៀបចំ



ពេលកំពុងរៀបចំ



ទិដ្ឋភាពក្នុងការិយាល័យក្រោយរៀបចំរួច

## ការជួបសំដែងការគួរសមចំពោះឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ពេលដែលគំរោងចាប់ផ្តើមដំបូងនៅថ្ងៃទី ២៨ ខែកក្កដា ក្រុមការងារគំរោង បានជួបសំដែងការគួរសមជាមួយ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ លោកស្រីប្រធាន-ទីប្រឹក្សាគំរោង Fujita បានជំរាបជូនឯកឧត្តមរដ្ឋមន្ត្រី អំពីចំនាប់អារម្មណ៍របស់គាត់ដែលមាន២ចំនុចដូចតទៅ: ចំនុច-ទី១ ក្រសួងសុខាភិបាលបាន ធ្វើអោយប្រសើរឡើង វិញ្ញូ-វស្ថានភាពគ្រូបង្រៀនផ្នែកអមវេជ្ជសាស្ត្រ ជាពិសេស បង្កើន-នូវស្ថានភាពថវិកា ដើម្បីជំរុញការផលិតធនធាន មនុស្ស។ ចំនុចទី២ ក្រសួងសុខាភិបាលបាន ធ្វើសកម្មភាព ក្នុងការ-បង្កើតច្បាប់លិខិតបទដ្ឋានជាមូលដ្ឋានសំរាប់ការ អភិវឌ្ឍន៍ធនធានមនុស្សដើម្បីបង្គ្រប់ច្បាប់ និង លិខិតបទដ្ឋាន ផ្សេងៗទៀតដែលមានស្រាប់។ ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល សង្ឃឹមយ៉ាងមុតមាំចំពោះ ការ-បង្កើត ច្បាប់ជាគោលការណ៍នេះ។ ការជួបសំដែងការគួរសម រវាង ឯកឧត្តម ម៉ម ប៊ុនហេង និង លោកស្រីប្រធានទីប្រឹក្សា គំរោង Fujita បានបញ្ចប់ទៅ ដោយភាពស្និទ្ធស្នាល និង រាក់ទាក់។



ខាងស្តាំ ឯកឧត្តម ម៉ម ប៊ុនហេង និង
ខាងឆ្វេង លោកស្រីប្រធានទីប្រឹក្សាគំរោង Fujita



ពីឆ្វេងទី១ លោកស្រីជំនាញការ Mochizuki

## ការចូលរួមក្នុងសិក្ខាសាលាEDC

នាពេលបច្ចុប្បន្ននេះ ក្នុងប្រទេសកម្ពុជាមាន ម្ចាស់ជំនួយ ជាច្រើនដែលកំពុងផ្តល់ ជំនួយក្នុង ការអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល។ ក្នុងស្ថានភាពនេះ អង្គការសុខភាពពិភពលោក WHO សហការណ៍ ជាមួយក្រសួងសុខាភិបាល និង សកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល (University of Health Sciences) បានបង្កើត សិក្ខាសាលាមួយដែលមានឈ្មោះថា EDC (Educational Development Center មាន-រយះពេល ២ថ្ងៃ គឺពីថ្ងៃទី៤ ដល់ទី៥ ខែកក្កដា ឆ្នាំ២០១០ នៅសកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ។ សិក្ខាសាលានេះ ត្រូវបាន រំពឹងទុកថាជា មូលដ្ឋានគ្រឹះក្នុងការពង្រឹងសមត្ថភាពគ្រូបង្រៀនថ្មី និងគ្រូដែលមានស្រាប់។ ទោះបីជាមានគំនិត ក្នុង-ការផ្តួចផ្តើមបង្កើត EDC ក៏ដោយ ការចូលរួមរបស់គំរោង គឺជាមធ្យោបាយល្អមួយ ផងដែរ។



*ការចូលរួមនៃជំនាញការជប៉ុន និង CP*

## ដំណើរការនៃគំរោង

*ថ្ងៃទី២២ ខែ មិថុនា៖ ការចូលកាន់ដំណែងរបស់អ្នកសំរបសំរួលគំរោង គឺលោក KOJIMA*
*ថ្ងៃទី១ ខែកក្កដា៖ ការចូលកាន់ដំណែងនៃប្រធានគំរោង FUJITA រហូតដល់ថ្ងៃទី២៨ ខែសីហា*
*ថ្ងៃទី២ ខែកក្កដា៖ ជួបសំដែងការគួរសមជាមួយលោកស្រីប្រធាន HRD គាត ភួង*
*ថ្ងៃទី ៣ ខែកក្កដា៖ ជំនាញការ Mochizuki មកដល់ រហូតដល់ថ្ងៃទី ១ ខែសីហា*
*ថ្ងៃទី ៥ ខែកក្កដា៖ ជួបប្រជុំជាមួយលោកស្រីប្រធាន HRD គាត ភួង*
*ថ្ងៃទី៦ ខែកក្កដា៖ ជួបប្រជុំជាមួយ JICA ប្រចាំនៅកម្ពុជា*
*ថ្ងៃទី ៧ - ៨ ខែកក្កដា៖ ចូលរួមសិក្ខាសាលា EDC*
*ថ្ងៃទី ៩ ខែកក្កដា៖ ការប្រជុំជាប្រចាំធម្មតា (RM)*
*ថ្ងៃទី ១២ ខែកក្កដា ៖ ការជួបសំដែងការគួរសមជាមួយលោកអនុរដ្ឋលេខាធិកា សៀ គ្រុយ និង សាស្ត្រាចារ្យ រដ្ឋលេខាធិកា អេង ហួត*
*ថ្ងៃទី ១៣ ខែកក្កដា៖ ការជួបប្រជុំជាមួយលោកទីប្រឹក្សា HRD លោកវេជ្ជ, លឹម ហ៊ុយ នៃអង្គការ GTZ*
*ថ្ងៃទី ១៤ ខែកក្កដា៖ ការជួបប្រជុំជាមួយ JICA ប្រចាំនៅកម្ពុជា*
*ថ្ងៃទី ១៥ ខែកក្កដា៖ ចូលរួមកិច្ចប្រជុំរៀបចំសមាគមគិលានុដ្ឋាន និង ការប្រជុំឆ្លប core competency*
*ថ្ងៃទី ១៦ ខែកក្កដា៖ RM និង ការប្រជុំជំនាញការ (TM)*
*ថ្ងៃទី ១៩ ខែកក្កដា ៖ ការប្រជុំជាមួយជំនាញការ WHO (Ms. Ann) និង ការប្រជុំរវាងជំនាញការ និង សមភាគី ដើម្បីពិនិត្យលើ PDM*
*ថ្ងៃទី ២០ ខែកក្កដា៖ ជួបសំដែងការគួរសមជាមួយសកលវិទ្យាធិកា UHS និង អគ្គនាយកសុខាភិបាល*
*ថ្ងៃទី ២១ ខែកក្កដា៖ ប្រមូលទិន្នន័យនៅ UNFPA និង TSMC*
*ថ្ងៃទី ២២ ខែកក្កដា៖ ដំណើរទស្សនៈកិច្ចនៅមន្ទីរពេទ្យកុមារអង្គរ (ខេត្តសៀមរាប) រហូតដល់ថ្ងៃទី ២៣*
*ថ្ងៃទី ២៣ ខែកក្កដា៖ ជួបប្រជុំជាមួយអ្នកទទួលខុសត្រូវគំរោងនៅJICA កម្ពុជា និង ប្រមូលពត៌មាននៅ NMCHC*
*ថ្ងៃទី ២៦ ខែកក្កដា៖ ប្រមូលពត៌មានពីក្រុមប្រឹក្សាឆ្មប*
*ថ្ងៃទី ២៧ ខែកក្កដា៖ សេចក្តីរាយការរបស់ជំនាញការ Mochizuki*
*ថ្ងៃទី ២៨ ខែកក្កដា ៖ ការជួបប្រជុំជាមួសកលវិទ្យាធិកា និង ប្រមូលពត៌មានពីប្រធានផ្នែកគិលានុដ្ឋាក ឆ្មបនៃ ក្រសួងសុខាភិបាល និង សំដែងការគួរសមចំពោះឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល។*
*ថ្ងៃទី ២៩ ខែកក្កដា ៖ ប្រមូលពត៌មាននៅគំរោងធ្វើអោយប្រសើរឡើងនូវសាលាអប់រំចៅក្រម និង ព្រះរាជអញ្ញា និង គំរោងនៃមន្ទីរពេទ្យកុមារ។*
*ថ្ងៃទី ២៩ ខែកក្កដា៖ RM・TM*